# ការវិភាគច្បាប់៖ បទរុកកួនខាងផ្លូវភេទ(ការបៀតបៀនផ្លូវភេទ) ក្នុងប្រទេសកម្ពុជា

ការសិក្សាស្រាវជ្រាវនេះ គាំទ្រដោយអង្គការឃែរក្នុងឆ្នាំ២០១៤ ដើម្បីផ្តល់នូវការវិភាគលម្អិតមួយអំពីវិធានការនានាដែលមាននៅក្នុងច្បាប់ការងារក្រមព្រហ្មទណ្ឌ និងក្របខណ្ឌគោលនយោបាយនានារបស់ប្រទេសកម្ពុជា ពាក់ព័ន្ធនឹងការរុកកួនផ្លូវភេទ(ការបៀតបៀនផ្លូវភេទ) និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ការសិក្សានេះត្រូវ បានធ្វើឡើងតាមរយៈ ការវិភាគទិន្នន័យដែលមានស្រាប់ ការសម្ភាសជាបុគ្គល និងការពិភាក្សាជាក្រុម ។

ការសិក្សាស្រាវជ្រាវនេះ គឺពិនិត្យលើមាត្រាច្បាប់ និងយន្តការនានាដែលមានស្រាប់ក្នុងការឆ្លើយតបទៅនឹងបទរុកកួនផ្លូវភេទ(ការបៀតបៀនផ្លូវភេទ) និងអំពើហិង្សាទាក់ទងនឹងយេនឌ័រក៏ដូចជាតួនាទីរបស់អ្នកដែលមានតួនាទីទទួលខុសត្រូវក្នុងការអនុវត្ត។ វិធីសាស្ត្របែបនេះផ្តល់នូវព័ត៌មានមួយដែលមានលក្ខខណៈគ្រប់ជ្រុង ជ្រោយអំពីច្បាប់ និងការអនុវត្តច្បាប់ជាក់ស្តែង។

ការស្រាវជ្រាវនេះបង្ហាញឲ្យឃើញនូវឱកាសនានាក្នុងការធ្វើឲ្យកាន់តែប្រសើរឡើងទាំងកម្រិតនៃការកែទម្រង់ និងការអនុវត្តច្បាប់។ ការសិក្សានេះក៏ពិនិត្យទៅលើអ្នកដែលមានតួនទីទទួលខុសត្រូវផ្សេងទៀតផងដែរដូចជា និយោជក និងអង្គការមិនមែនរដ្ឋាភិបាលនានាអាចធ្វើការរួមគ្នាដូចម្តេចខ្លះជាមួយក្រសួងពាក់ព័ន្ធផ្សេងៗក្នុងការដោះស្រាយបញ្ហាទាំងអស់នោះ។

ជារួមការសិក្សានេះបង្ហាញថា ទោះជាកំណែទម្រង់ច្បាប់តែមួយមុខក្តី ឬការលើកកម្ពស់ការអនុវត្តច្បាប់តែមួយមុខក្តី ក៏វាមិនអាចធានានូវការការពារដ៏ល្អបំផុតបានដែរ ។ ទាំងពីរមុខនេះ ចាំបាច់ត្រូវធ្វើការទន្ទឹមគ្នាក្នុងការផ្តល់ការការពារ និងឆ្លើយតបចំពោះការរុកកួនផ្លូវភេទ (ការបៀតបៀនផ្លូវភេទ) និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

## របកគំហើញសំខាន់ៗ

### នៅកម្រិតអន្តរជាតិ ការបៀតបៀនផ្លូវភេទត្រូវបានគេចាត់ទុកថាជាការរើសអើងផ្លូវភេទផង និងជាទម្រង់មួយនៃអំពើហិង្សាលើស្ត្រីផង

- អង្គការពលកម្មអន្តរជាតិ បានបញ្ជាក់អំពីការរុកកួនខាងផ្លូវភេទ (ការបៀតបៀនផ្លូវភេទ)នៅក្នុងឯកសារជាច្រើន។ អនុសញ្ញាលេខ១១១ស្តីពីការរើសអើងក្នុងការងារ និងមុខរបរនាឆ្នាំ ១៩៥៨ លើកឡើងអំពីការរើសអើងនៅក្នុងការងារដោយសារមូលហេតុជាច្រើន ក្នុងនោះរួមមានមូលហេតុផ្លូវភេទផងដែរ
- នៅឆ្នាំ១៩៨៩ គណៈកម្មាធិការទទួលបន្ទុកលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី បានទទួលស្គាល់ថាបទរុកកួនខាងផ្លូវភេទ (ការបៀតបៀនផ្លូវភេទ) នៅកន្លែងធ្វើការ គឺជាទម្រង់មួយនៃអំពើហិង្សាក្នុងជីវិតប្រចាំថ្ងៃ
- នៅឆ្នាំ១៩៩២ គណៈកម្មាធិការទទួលបន្ទុកលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី បានបញ្ជាក់ថា “សមភាពក្នុងការងារអាចត្រូវបានប៉ះពាល់យ៉ាងខ្លាំង កាលណាស្ត្រីត្រូវទទួលរងនូវអំពើហិង្សាផ្អែកយេនឌ័រ ដូចជាការរុកកួនផ្លូវភេទ (ការបៀតបៀនផ្លូវភេទ) នៅកន្លែងធ្វើការជាដើម”។

### រដ្ឋធម្មនុញ្ញកម្ពុជា គឺជាមូលដ្ឋានគ្រឹះនៃច្បាប់ជាតិសម្រាប់ការពារអំពើហិង្សាទាក់ទង នឹង យេនឌ័រ និងការរុកកួនផ្លូវភេទ (ការបៀតបៀនផ្លូវភេទ)

- មាត្រា៣១នៃរដ្ឋធម្មនុញ្ញ ផ្តល់ការទទួលស្គាល់នឹងការគោរពចំពោះសិទ្ធិមនុស្ស ដូចដែលមានចែងនៅក្នុងអនុសញ្ញាអន្តរជាតិនានាមានបញ្ជាក់ច្បាស់លាស់គឺ សិទ្ធិស្ត្រី ហើយមាត្រា៤៥ចែងអំពីការបញ្ចប់រាល់ទម្រង់នៃការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រី ។
- ច្បាប់ជាតិផ្សេងទៀតដែលមានលើកឡើងអំពីទម្រង់នៃអំពើហិង្សាប្រឆាំងនឹងស្ត្រី មានដូចជាច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទច្បាប់ស្តីពីការងារ និងក្រមព្រហ្មទណ្ឌ ។

### មាត្រា១៧២នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ហាមឃាត់ការរំលោភបំពានផ្លូវភេទ ប៉ុន្តែគេនៅតែមិនទាន់ច្បាស់ថាតើនឹងត្រូវអនុវត្តមាត្រានោះដូចម្តេចចំពោះការរុកកួនផ្លូវ ភេទ(ការបៀតបៀនផ្លូវភេទ)នៅកន្លែងការងារ

- ដោយហេតុថាគ្មានការដាក់ទោសទណ្ឌចំពោះការមិនគោរពមាត្រា១៧២នៃច្បាប់ស្តីពីការងារ មានន័យថាមាត្រានេះអាចអនុវត្តបានដោយយោងតាមមាត្រានានានៅក្នុងក្រមព្រហ្មទណ្ឌ ។
- ស្របគ្នាទៅនឹងមាត្រា១៧២នៃច្បាប់ការងារ ប្រកាសលេខ១៩៤ ស្តីពីលក្ខខណ្ឌការងារ វិធានអនាម័យ និង សន្តិសុខការងារនៃសហគ្រាស គ្រឹះស្ថានក្រុមហ៊ុនផ្អែកសេវាកំសាន្ត ដែលបានធ្វើឡើងដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មិនអាចផ្តល់នូវខ្លឹមសារច្បាស់លាស់ដែលអាចអនុវត្តបានប្រសើរជាងមាត្រា ១៧២ នោះទេ ។
- បទរុកកួនខាងផ្លូវភេទ(ការបៀតបៀនផ្លូវភេទ) មិនត្រូវបានដាក់បញ្ចូលទៅក្នុងតារាង ត្រួតពិនិត្យ និងតាមដានរបស់ក្រុមអធិការកិច្ចនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅឡើយ ដើម្បីធ្វើឲ្យប្រាកដថាស្ថាប័ននានាកំពុងអនុវត្តតាមច្បាប់ស្តីពីការងារ ។

### ជំពូកទី៣ នៃក្រមព្រហ្មទណ្ឌ ២០០៩ បានធ្វើចំណាត់ថ្នាក់ទម្រង់នៃការបំពានខាងផ្លូវភេទ ព្រមទាំងចែងអំពីការពិន័យជាប្រាក់ និងលក្ខខណ្ឌនានានៃការដាក់ពន្ធនាគារចំពោះបទល្មើសទាំងនោះ

- បទរំលោភសេពសន្ថវៈ (មាត្រា២៣៩) គឺជាបទឧក្រិដ្ឋ បទប្រទូស្តកេរ្តិ៍ខ្មាស(មាត្រា២៤៦) គឺជាបទល្មើសមជ្ឈឹមហើយការរំលោភបំពានដែលមានចែងមាត្រាទាំងពីរ គឺសំដៅលើការរំលោភបំពានផ្នែករាងកាយ ។
- បទបង្ហាញកេរភេទ(មាត្រា២៤៩)និងបទរុកកួនខាងផ្លូវភេទ(មាត្រា២៥០) គឺជាបទល្មើសមជ្ឈឹម។

- និយមន័យនៃបទរុកកួនផ្លូវភេទ (ការបៀតបៀនផ្លូវភេទ) គឺមានចែងអំពីតែការបំពានអំណាចប៉ុណ្ណោះ "បទរុកកួនខាងផ្លូវភេទ គឺជាអំពើដែលបុគ្គលម្នាក់ រំលោភអំណាចដែលមុខងារខ្លួនប្រគល់ឲ្យធ្វើការកៀបសង្កត់ម្តងហើយម្តងទៀតទៅលើអ្នកដទៃក្នុងគោលបំណងទទួលបានការអនុគ្រោះខាងផ្លូវភេទ"
- ជនរងគ្រោះនៃអំពើណាមួយក្នុងចំណោមអំពើទាំងនោះអាចដាក់ពាក្យបណ្តឹងទៅនគរបាលយុត្តិធម៌ (ប៉ូលីស និងកងរាជអាវុធហត្ថ) ឬទៅកាន់តុលាការ ដើម្បីចោទប្រកាន់ពីបទព្រហ្មទណ្ឌនិងទាមទារសំណងរដ្ឋប្បវេណី។មានតែតុលាការទេទើបអាចសម្រេចសេចក្តីបានមានទោសហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ទោសពិន័យ និងផ្តល់សំណងរដ្ឋប្បវេណីដល់ជនរងគ្រោះ។

## មាត្រានានានៅក្នុងក្រមព្រហ្មទណ្ឌមិនមានចែងច្បាស់លាស់ទេថាតើអាកប្បកិរិយាណាខ្លះដែលគួរចាត់ទុកថាជាបទរុកកួនខាងផ្លូវភេទ (ការបៀតបៀនផ្លូវភេទ)

- បទរុកកួនខាងផ្លូវភេទ (ការបៀតបៀនផ្លូវភេទ) នៅកន្លែងធ្វើការនឹងអាចអនុវត្តទៅតាមក្រមព្រហ្មទណ្ឌបានប្រសិនបើវាជាការរុកកួនផ្នែករាងកាយបទរំលោភសេពសន្ថវៈ ឬការបំពានផ្លូវភេទ)កើតឡើងដោយសារទំនាក់ទំនងអំណាច (បទរុកកួនខាងផ្លូវភេទ) ឬការបង្ហាញនូវសរីរាង្គភេទ(បទបង្ហាញកេរភេទ)
- នៅក្នុងក្របខណ្ឌច្បាប់ និងគោលនយោបាយក្នុងប្រទេសកម្ពុជា មិនបានលើកឡើងទេ អំពីអាកប្បកិរិយាដែលមានលក្ខណៈផ្លូវភេទផ្សេងៗទៀតជាអាកប្បកិរិយា ដែលគេមិនចូលចិត្ត ហើយបង្កការរំខាន ឬបង្កការភិតភ័យ ឧទាហរណ៍ ការរុកកួនដោយពាក្យសំដី មានដូចជាការពោលពាក្យ ឬការសួរអំពីទំនាក់ទំនង ឬអំពីលក្ខណៈរាងកាយ ឬមួយអាកប្បកិរិយាដោយមិនប្រើពាក្យសំដីនានា ដូចជាកាយវិការទាក់ទងនឹងផ្លូវភេទ ឬការបង្ហាញ សម្ភារៈទាក់ទងនឹងផ្លូវភេទ។
- និយមន័យទាំងអស់នេះ មិនមានរាប់បញ្ចូលទេ នូវបទរុកកួនខាងផ្លូវភេទនៅកន្លែងធ្វើការ ដែលប្រព្រឹត្តឡើងដោយអ្នករួមការងារម្នាក់ទៅម្នាក់ទៀតដែលបណ្តាលឲ្យបរិស្ថានការងារមិនល្អ (អាប់អួរ)

## នីតិវិធីក្នុងការដាក់ពាក្យបណ្តឹង និងនីតិវិធីស៊ើបអង្កេតមានចែងនៅក្នុងច្បាប់ ចំពោះអំពើទាំងឡាយណាដែលល្មើសនឹងក្រមព្រហ្មទណ្ឌ ប៉ុន្តែមានពាក្យបណ្តឹងតិចតួចប៉ុណ្ណោះដែលត្រូវបានធ្វើឡើង ហើយជារឿយៗពាក្យបណ្តឹងទាំងនោះមិនត្រូវបានគេយកមកចាត់ការទេ ។

- ការជម្រះក្តីអំពីបទរុកកួនខាងផ្លូវភេទ គឺអនុវត្តទៅតាមក្រមព្រហ្មទណ្ឌ ហើយនីតិវិធីសម្រាប់ការអនុវត្តគឺមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ។ នីតិវិធីទាំងនោះរួមមានការដាក់បណ្តឹងទៅនគរបាលយុត្តិធម៌ នគរបាលយុត្តិធម៌កសាង និងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ និងបញ្ជូន សំណុំរឿងទៅចៅក្រមស៊ើបអង្កេតដើម្បីបើកការស៊ើបអង្កេតការស៊ើបអង្កេត និងការ ជំនុំជម្រះក្តីនៅតុលាការ
- ជនរងគ្រោះមិនមានអារម្មណ៍សុខស្រួលក្នុងការអនុវត្តសិទ្ធិរបស់ខ្លួនតាមរយៈតុលាការទេ ដោយហេតុថាពួកគេត្រូវចំណាយពេលវេលាយូរ អស់ថវិកាច្រើន និងមិនជឿជាក់លើប្រព័ន្ធយុត្តិធម៌
- មានស្ថានភាពខ្លះ អ្នកមានតួនាទីទទួលខុសត្រូវ មិនអនុវត្តច្បាប់ ដែលធ្វើឲ្យជនរងគ្រោះបាក់ទឹកចិត្តក្នុងការដាក់ពាក្យបណ្តឹង
- វិវាទនានាត្រូវបានដោះស្រាយ "ក្រៅប្រព័ន្ធតុលាការ" ហើយពេលខ្លះការដោះស្រាយត្រូវបានធ្វើឡើងដោយបង់ថវិកាទៅឲ្យជនរងគ្រោះ

## ចំពោះអំពើទាំងឡាយណាដែលមានចែងនៅក្នុងនិយមន័យជាអន្តរជាតិអំពីបទរុកកួនខាងផ្លូវភេទ ប៉ុន្តែមិនមានបញ្ជាក់នៅក្នុងក្រមព្រហ្មទណ្ឌនៃប្រទេសកម្ពុជា វាជាឱកាសមួយ សម្រាប់អ្នកមានតួនាទីទទួលខុសត្រូវនានាដូចជា និយោជក អង្គការមិនមែនរដ្ឋាភិបាល នឹងក្រសួងពាក់ព័ន្ធក្នុងការរកដំណោះស្រាយផ្សេងទៀត

- ការបង្កើតឲ្យមានគោលនយោបាយស្តីពីបទរុកកួនផ្លូវភេទ (ការបៀតបៀនផ្លូវភេទ)នៅកន្លែងធ្វើការនីមួយៗអាចផ្តល់ជាយន្តការមួយ សម្រាប់ទប់ស្កាត់អាកប្បកិរិយាបៀតបៀនផ្លូវភេទនានាដែលមិនមានចែងក្នុងមាត្រានៃក្រមព្រហ្មទណ្ឌ
- ដើម្បីធ្វើឲ្យគោលនយោបាយស្តីពីបទរុកកួនផ្លូវភេទនៅកន្លែងធ្វើការទទួលបានលទ្ធផលតាមការការរំពឹងទុករបស់វា ចាំបាច់ត្រូវឲ្យបុគ្គលិកនិងថ្នាក់ដឹកនាំនៃស្ថាប័ននីមួយៗយល់ឲ្យបានច្បាស់ពីគោលនយោបាយនោះ។

### អនុសាសន៍គោលនយោបាយ

ការសិក្សាស្រាវជ្រាវនេះបានចង្អុលបង្ហាញនូវឱកាសនានាសម្រាប់៖

- ការអនុវត្តច្បាប់ និងបទដ្ឋានក្រោមច្បាប់នានាដែលមានក្នុងពេលបច្ចុប្បន្ន
- ការកែទម្រង់ច្បាប់ទាក់ទងនឹងការរុកកួនផ្លូវភេទក្នុងកន្លែងការងារ
- រោងចក្រ និងស្ថាប័នកំសាន្តនានាអនុវត្តវិធានការផ្សេងៗទៀតសម្រាប់ដោះ ស្រាយបទរុកកួនផ្លូវភេទ(ការបៀតបៀនផ្លូវភេទ) នៅកន្លែងធ្វើការ។

ការវិភាគច្បាប់៖បទរុកកួនខាងផ្លូវភេទ( ការបៀតបៀនផ្លូវភេទ) នៅក្នុងប្រទេសកម្ពុជាដោយលោក លាង ឡូ និងលោក អុប វិបុល